# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៦២ ព.ណ. ករបប.ប្រក

# ប្រកាស
## ស្ដីពី
## នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១១៤/០០៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងអនុវត្តបទប្បញ្ញត្តិនៃច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឲ្យបានកាន់តែមានប្រសិទ្ធភាព ។

**ប្រការ២.- គោលដៅ**

ប្រកាសនេះមានគោលដៅ៖

- កំណត់វិធាន និងនីតិវិធីស្តីពី ការគ្រប់គ្រង ការចុះបញ្ជី ការទទួលស្គាល់ និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ
- ការពារកម្មសិទ្ធិបញ្ញារបស់ផលិតករ ប្រតិបត្តិករ និងអ្នកប្រើប្រាស់ផលិតផលសម្គាល់ភូមិសាស្ត្រ
- អភិរក្ស និងពង្រឹងចំណេះដឹង ចំណេះធ្វើតាមបែបប្រពៃណី និងអត្តសញ្ញាណជាតិ
- បង្កើតការងារនៅជនបទ អភិវឌ្ឍសហគមន៍ក្នុងស្រុក កាត់បន្ថយភាពក្រីក្រ និងទាក់ទាញភ្ញៀវទេសចរណ៍ ។

**ប្រការ៣.- វាក្យសព្ទបច្ចេកទេស**

វាក្យសព្ទបច្ចេកទេសដែលបានប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- "ច្បាប់" សំដៅដល់ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- "ម៉ាកសម្គាល់ភូមិសាស្ត្រ" សំដៅដល់ "ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ" ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់
- "សមាគមសម្គាល់ភូមិសាស្ត្រ" សំដៅដល់ ក្រុមតំណាងផលិតករ អង្គភាពផលិតករ និង/ឬ ប្រតិបត្តិករ ដែលទទួលផលប្រយោជន៍ពីម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់ និងត្រូវបានទទួលស្គាល់ជាម្ចាស់នៃម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីរួច
- "ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ" សំដៅដល់ "ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ" ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ គឺជាក្រុមប្រឹក្សាអន្តរក្រសួងដែលបង្កើតឡើងដោយអនុក្រឹត្យ ដើម្បីសិក្សាជំរុញ និងអភិវឌ្ឍផលិតផលសក្តានុពលសម្រាប់ធ្វើការចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោះស្រាយបណ្តឹងតវ៉ាទាក់ទងនឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ
- "អ្នកដាក់ពាក្យស្នើសុំ" សំដៅដល់សមាគមសម្គាល់ភូមិសាស្ត្រ ក្នុងគោលបំណងដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រណាមួយ
- "ទំនិញ" សំដៅដល់ទំនិញកសិផល ទំនិញកសិចំណីអាហារ ទំនិញសិប្បកម្ម ឬទំនិញផ្សេងៗទៀតដែលផលិត ឬកែច្នៃក្នុងតំបន់ភូមិសាស្ត្រនោះ
- "រូបសញ្ញាជាតិ" សំដៅដល់ និមិត្តសញ្ញាដែលប្រើប្រាស់សម្រាប់បញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ និងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមាន

ចែងក្នុងមាត្រា ១៤ នៃច្បាប់

- "PGI" សំដៅដល់ "ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារ" ជាភាសាខ្មែរ ឬ "Protected Geographical Indication" ជាភាសាអង់គ្លេស ឬការបកប្រែទៅជាភាសាណាមួយ
- "មន្ត្រីកាន់កាប់បញ្ជី" សំដៅដល់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលទទួលបន្ទុកពិនិត្យ និងសម្រេចចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ និងកិច្ចការពាក់ព័ន្ធ
- "អាជ្ញាធរមានសមត្ថកិច្ច" សំដៅដល់ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## អាជ្ញាធរមានសមត្ថកិច្ច

### ប្រការ៤.- ភារកិច្ចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

នាយកដ្ឋានកម្មសិទ្ធិបញ្ញាជាសេនាធិការរបស់ក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចខាងក្រោម៖

- ទទួលនិងត្រួតពិនិត្យទម្រង់ និងខ្លឹមសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ
- ត្រួតពិនិត្យសៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹងជំទាស់ សេចក្តីថ្លែងតប និងបណ្តឹងតវ៉ា
- ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ កែតម្រូវ កែសម្រួល ធ្វើមោឃភាព និងលុបម៉ាកសម្គាល់ភូមិសាស្ត្រ
- សម្រុះសម្រួលវិវាទពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដូចជាសវនាការក្នុងនីតិវិធីបណ្តឹងជំទាស់
- ពិនិត្យ និងសម្រេចកិច្ចការផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ
- បោះពុម្ពផ្សាយរាល់ការចុះបញ្ជី ការកែតម្រូវ ការកែសម្រួល ការធ្វើមោឃភាព និងការលុបការចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រក្នុងព្រឹត្តិបត្រផ្លូវការ
- គ្រប់គ្រង និងផ្តល់ការអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ
- ពិនិត្យ និងពិចារណាលើការណែនាំផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលទទួលបានដោយក្រសួងពាណិជ្ជកម្ម
- អនុវត្តតាមសេចក្តីណែនាំ អនុសាសន៍ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬតុលាការ
- តម្កល់ទុករាល់បញ្ជីការ និងឯកសារពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ
- ជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ដែលអនុវត្តកិច្ចការផ្សេងៗទៀតពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ។

## ជំពូកទី៣
## នីតិវិធីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

## ផ្នែកទី១
## ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

### ប្រការ៥.- អ្នកដាក់ពាក្យស្នើសុំ

១. ដោយអនុលោមតាមមាត្រា ៧ នៃច្បាប់ អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីលទ្ធភាពរបស់ខ្លួន ដើម្បីការពារនិងគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រ ។

អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

ក. ព្រាងសៀវភៅបន្ទុកចូលរួមចំណែកដល់ការអនុវត្តតាមសៀវភៅបន្ទុក ពីបណ្តាផលិតករ សមាជិក និងប្រតិបត្តិករ ព្រមទាំងចូលរួមក្នុងការអនុវត្តផែនការត្រួតពិនិត្យ ជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង

ខ. តម្កល់ទុកបញ្ជីផលិតករ និង/ឬប្រតិបត្តិករនៃម៉ាកសម្គាល់ភូមិសាស្ត្រ ហើយត្រូវបញ្ជូនបញ្ជីនោះទៅអង្គភាពត្រួតពិនិត្យ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម

គ. ចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ ជាពិសេស ឈ្មោះ និងដែនដី ការវាយតម្លៃអំពីផលិតផល ព្រមទាំងចំណេះដឹងផ្នែកស្ថិតិនៃចង្វាក់តម្លៃ ។

២. នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ឯកសារមួយចំនួនមកនាយកដ្ឋានកម្មសិទ្ធិញ្ញានៃក្រសួងពាណិជ្ជកម្ម ដូចខាងក្រោម៖

ក. វិធាន និងបទបញ្ជាគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាព ឬសមាគម ប្រសិនបើមានព័ត៌មានដែលប្រើប្រាស់សម្រាប់វាយតម្លៃលើភាពជាអ្នកតំណាងនៃផលិតករ និង/ឬប្រតិបត្តិករ ហើយទ្រង់ទ្រាយតំណាងឲ្យប្រភេទផ្សេងៗគ្នានៃប្រតិបត្តិករសម្រាប់ផលិតផល ដែលកំពុងស្នើសុំត្រូវឲ្យមានតុល្យភាពនឹងគ្នា

ខ. ព័ត៌មានស្តីពីអង្គភាពនិងធនធាន ដែលបានលះបង់ចំពោះកិច្ចការ ដូចបានកំណត់ក្នុងកថាខណ្ឌ (១)

គ. អនុវត្តតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ។

៣. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចតម្រូវឲ្យអ្នកស្នើសុំផ្តល់ព័ត៌មានបន្ថែម ដើម្បីពិចារណាអំពីការទទួលស្គាល់សមាគម ហើយប្រតិបត្តិករទាំងនោះ ត្រូវមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រ ដោយមិនត្រូវបង្កឧបសគ្គដល់ការចូលរួម ដែលនាំឲ្យមានការរើសអើង ឬលើកលែងតែមានគោលដៅផ្ទុយពីនេះ ។

## ប្រការ៦.- ផលិតករ ឬប្រតិបត្តិករតែមួយ

១. ក្នុងករណីដែលរូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ អាចត្រូវបានចាត់ទុកជាសមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុមបាន លុះត្រាតែសមាគមនោះបានបំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

ក. បុគ្គលពាក់ព័ន្ធជាផលិតករតែម្នាក់គត់ ដែលមានឆន្ទៈក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជី

ខ. ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ តំបន់ភូមិសាស្ត្រដែលបានកំណត់ត្រូវមានចរិតលក្ខណៈដែលធ្វើឲ្យខុសគ្នាដាច់ពីបណ្តាតំបន់ភូមិសាស្ត្រជិតខាង ឬចរិតលក្ខណៈនៃផលិតផល ត្រូវមានលក្ខណៈខុសពីផលិតផលដែលបានផលិតក្នុងបណ្តាតំបន់ជិតខាងនោះ ។

២. យោងតាមកថាខ័ណ្ឌ១ សមាគមសម្គាល់ភូមិសាស្ត្រ ឬក្រុម ដែលស្ថិតក្រោមស្ថានភាពបែបនេះនៅតែបើកចំហរចំពោះផលិតករ ឬប្រតិបត្តិករថ្មី ដែលមានឆន្ទៈអនុវត្តតាមវិធាននៃម៉ាកសម្គាល់ភូមិសាស្ត្រ ។

## ប្រការ៧.- សមាគមសម្គាល់ភូមិសាស្ត្រ

១. ដោយមិនធ្វើឲ្យប៉ះពាល់បទប្បញ្ញត្តិជាក់លាក់ស្តីពីអង្គភាពផលិតករ និងអន្តរសាខានៃអង្គភាព

នោះ សមាគមសម្គាល់ភូមិសាស្ត្រមានសិទ្ធិដើម្បី៖

ក. ចូលរួមចំណែកក្នុងការធានាថា គុណភាព កិត្តិសព្ទ និងភាពត្រឹមត្រូវនៃផលិតផលរបស់អង្គភាពត្រូវបានធានានៅលើទីផ្សារ តាមរយៈការត្រួតពិនិត្យការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រក្នុងវិស័យពាណិជ្ជកម្ម ហើយក្នុងករណីចាំបាច់ ត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងជំពូកទី ២ នៃច្បាប់

ខ. ចាត់វិធានការដើម្បីធានាឲ្យមានកិច្ចការពារតាមផ្លូវច្បាប់ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីរួច និងសិទ្ធិកម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រទាំងនោះ

គ. បង្កើតព័ត៌មាន និងសកម្មភាពផ្សព្វផ្សាយនានាអំពីតម្លៃបន្ថែម ដែលផ្សារភ្ជាប់នឹងផលិតផលទៅកាន់អ្នកប្រើប្រាស់

ឃ. បង្កើតសកម្មភាពពាក់ព័ន្ធនឹងការធានាថា ផលិតផលនោះអនុលោមតាមសៀវភៅបន្ទុក

ង. ចាត់វិធានការកែលំអ ការអនុវត្តផែនការ រួមទាំងជំនាញអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ការវិភាគផ្នែកសេដ្ឋកិច្ច ការផ្សព្វផ្សាយព័ត៌មានស្តីពីផែនការសេដ្ឋកិច្ច និងផ្តល់ការណែនាំដល់ផលិតករ

ច. ចាត់វិធានការលើកកម្ពស់តម្លៃផលិតផល ហើយក្នុងករណីចាំបាច់ ចាត់វិធានការទប់ស្កាត់ ឬប្រឆាំងនឹងវិធានការណាមួយ ដែលធ្វើឲ្យប៉ះពាល់ ឬបង្កហានិភ័យដល់រូបភាពផលិតផលទាំងនោះ ។

២. សមាគមសម្គាល់ភូមិសាស្ត្រ ត្រូវជូនដំណឹងអំពីព័ត៌មានណាមួយ ដែលពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចរបស់ខ្លួន តាមការតម្រូវរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

៣. សមាគមសម្គាល់ភូមិសាស្ត្រអាចបង្កើតវិធាន ស្តីពីការអនុវត្តល្អៗតាមបទប្បញ្ញត្តិកំណត់ ដើម្បីថែរក្សាចរិតលក្ខណៈបរិស្ថានជាក់ស្តែងនៃដី ឬបទប្បញ្ញត្តិជាក់លាក់ស្តីពីសុខុមាលភាពសត្វ ។

**ប្រការ៨.- ការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ**

១. អនុលោមតាមមាត្រា៨ នៃច្បាប់ អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២. ពាក្យស្នើសុំចុះបញ្ជីត្រូវធ្វើជាភាសាខ្មែរ ឬភាសាអង់គ្លេស ។ ឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីប្រសិនបើមិនបានធ្វើឡើងជាភាសាខ្មែរឬភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស ។

៣. ការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រត្រូវមាន៖

ក. ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងប្រការ ៩ នៃប្រកាសនេះ

ខ. ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ

គ. ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រ

ឃ. គំរូប្រភេទទំនិញដែលគ្របដណ្តប់ដោយពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

ង. សៀវភៅបន្ទុកដូចមានចែងក្នុងប្រការ ១០ នៃប្រកាសនេះ

ច. សេចក្តីសង្ខេបនៃសៀវភៅបន្ទុក

ឆ. វិក័យបត្របង់កម្រៃសេវា

ជ. ឯកសារពាក់ព័ន្ធផ្សេងៗទៀតទាក់ទងទៅនឹងការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ។

៤. ចំពោះការស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្របរទេសដូចមានចែងក្នុងជំពូកទី៥នៃច្បាប់ ត្រូវភ្ជាប់បន្ថែមមកជាមួយនូវភ័ស្តុតាងបញ្ជាក់ថា ឈ្មោះផលិតផលនោះត្រូវបានការពារក្នុងប្រទេសដើម ។

**ប្រការ៩.- ចំណុចសំខាន់ៗនៃពាក្យស្នើសុំពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ**

១. ទម្រង់ និងចំណុចសំខាន់ៗ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដោយយោងតាមប្រការ៨ នៃប្រកាសនេះ ត្រូវកំណត់និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២. ពាក្យស្នើសុំចុះបញ្ជីត្រូវមានព័ត៌មានសំខាន់ៗដូចខាងក្រោម៖

ក. ព័ត៌មានពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដោយមន្ត្រីកាន់កាប់បញ្ជី
- សេចក្តីយោងរបស់មន្ត្រីត្រួតពិនិត្យ
- ភ្នាក់ងារតំណាងក្នុងស្រុកសម្រាប់ទំនាក់ទំនង
- កាលបរិច្ឆេទនៃការដាក់ពាក្យ
- លេខដាក់ពាក្យ

ខ. ព័ត៌មានពាក់ព័ន្ធនឹងអ្នកដាក់ពាក្យស្នើសុំ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ
- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ប្រសិនបើពាក្យស្នើសុំចុះបញ្ជីដាក់តាមរយៈភ្នាក់ងារតំណាង

គ. ប្រភេទផ្សេងៗនៃពាក្យស្នើសុំ
- ពាក្យស្នើសុំចុះបញ្ជី
- ពាក្យស្នើសុំកែតម្រូវ ឬកែសម្រួលម៉ាកសម្គាល់ភូមិសាស្ត្រ
- ពាក្យស្នើសុំធ្វើមោឃភាព ឬលុបម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី
- ពាក្យស្នើសុំផ្សេងៗពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រ

ឃ. ឈ្មោះ និមិត្តសញ្ញា ឬសញ្ញានៃម៉ាកសម្គាល់ភូមិសាស្ត្រ

ង. ប្រភេទទំនិញដែលត្រូវការពារដោយម៉ាកសម្គាល់ភូមិសាស្ត្រ

ច. សេចក្តីពិពណ៌នាអំពីផលិតផល

ឆ. ជំពូកដែលទំនិញនោះស្ថិតនៅ (ទីក្រុងនីស)

ជ. តំបន់ភូមិសាស្ត្រនៃម៉ាកសម្គាល់ភូមិសាស្ត្រ

ឈ. សេចក្តីពិពណ៌នាអំពីវិធីសាស្ត្រនៃផលិតកម្ម

ញ. ចំណុចសំខាន់ៗ ដែលមានចំណងទាក់ទងគ្នា រវាងផលិតផលសម្គាល់ភូមិសាស្ត្រ និងប្រភពភូមិសាស្ត្រដើម

ដ. វិធីសាស្ត្រត្រួតពិនិត្យផលិតផលសម្គាល់ភូមិសាស្ត្រ

ឋ. ព័ត៌មានពាក់ព័ន្ធនឹងការដាក់ស្លាកសញ្ញានៃផលិតផលសម្គាល់ភូមិសាស្ត្រ

ឌ. ឯកសារនានាភ្ជាប់នឹងពាក្យស្នើសុំ

ឍ. ឯកសារផ្សេងៗទៀត

ណ. កាលបរិច្ឆេទនិងហត្ថលេខារបស់អ្នកដាក់ពាក្យស្នើសុំ។

៣. គំរូពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ អាចទាញយកបានពីគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ១០.- ខ្លឹមសារនៃសៀវភៅបន្ទុក**

ម៉ាកសម្គាល់ភូមិសាស្ត្រត្រូវអនុវត្តឲ្យស្របតាមសៀវភៅបន្ទុកដែលមានចំណុចសំខាន់ៗដូចខាងក្រោម៖

១. ឈ្មោះដែលត្រូវការពារជាម៉ាកសម្គាល់ភូមិសាស្ត្រ នៅពេលដែលឈ្មោះនោះត្រូវបានប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ឬជាភាសាទូទៅ ។

២. សេចក្តីពិពណ៌នាអំពីផលិតផលសម្រាប់ម៉ាកសម្គាល់ភូមិសាស្ត្រ ដែលត្រូវស្នើសុំចុះបញ្ជីរួមមាន៖ វត្ថុធាតុដើម ចរិតលក្ខណៈសំខាន់ៗផ្នែករូបរាង គីមី អតិសុខុមជីវសាស្ត្រ ឬសរីរៈវិញ្ញាណនៃផលិតផល ប្រសិនបើសមស្រប ។

៣. ការកំណត់តំបន់ភូមិសាស្ត្រ ត្រូវកំណត់ព្រំដែនដោយផ្អែកទៅលើចំណងទាក់ទង ដូចមានចែងក្នុងចំណុច ៦ នៃកថាខណ្ឌនេះ ។

៤. ភស្តុតាងដែលបញ្ជាក់ថា ផលិតផលនោះមានប្រភពក្នុងតំបន់ភូមិសាស្ត្រដែលបានកំណត់ ។

៥. សេចក្តីពិពណ៌នាអំពីវិធីសាស្ត្រក្នុងការទទួលបានផលិតផល ។

៦. សេចក្តីពិពណ៌នាលម្អិតដែលបង្កើតចំណងទាក់ទងរវាង គុណភាពដែលទទួលបានកិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃផលិតផល និងប្រភពភូមិសាស្ត្រដើម ។

៧. ឈ្មោះ និងអាសយដ្ឋានរបស់អង្គភាព ដែលពិនិត្យផ្ទៀងផ្ទាត់ភាពអនុលោមទៅនឹងបទប្បញ្ញត្តិនានានៃសៀវភៅបន្ទុកផលិតផល ។

៨. វិធីសាស្ត្រដែលប្រើប្រាស់ ដើម្បីត្រួតពិនិត្យផលិតផល ដោយផ្អែកទៅតាមដំណើរការនៃផលិតកម្ម និងអនុលោមតាមវិធានទូទៅដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ។

៩. វិធានស្តីពីការដាក់ស្លាកសញ្ញាជាក់លាក់ណាមួយ លើផលិតផលសម្គាល់ភូមិសាស្ត្រ ។

១០. ព័ត៌មានផ្សេងៗទៀត ប្រសិនបើចាំបាច់ ។

**ប្រការ១១.- ការដកពាក្យស្នើសុំ**

១. អ្នកស្នើសុំអាចដកពាក្យស្នើសុំនៅពេលណាក៏បាន ដោយជូនដំណឹងពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២. ក្នុងករណីដែលពាក្យស្នើសុំត្រូវបានដកតាមកថាខណ្ឌ(១) រាល់កម្រៃសេវាដែលបានបង់មកក្រសួងពាណិជ្ជកម្ម មិនអាចដកវិញបានឡើយ ។

## ផ្នែកទី២
## នីតិវិធីត្រួតពិនិត្យ

**ប្រការ១២.- ការកំណត់កាលបរិច្ឆេទនៃការដាក់ពាក្យ**

កាលបរិច្ឆេទនៃការដាក់ពាក្យ ត្រូវបានកំណត់នៅពេលដែលពាក្យស្នើសុំត្រូវបំពេញតាមលក្ខខណ្ឌទម្រង់ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់ ។

**ប្រការ១៣.- ការពិនិត្យពាក្យស្នើសុំ**

១. អនុលោមតាមកថាខណ្ឌ (២) មាត្រា ៩ នៃច្បាប់ បន្ទាប់ពីបានពិនិត្យឃើញថា ពាក្យស្នើសុំចុះបញ្ជី បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់ដែលបានកំណត់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យស្នើសុំនោះ ។

២. អនុលោមតាមកថាខណ្ឌ (៣) និង (៤) មាត្រា ៩ នៃច្បាប់ នៅពេលដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញាពិនិត្យឯកសារបន្ថែម ឬឯកសារកែតម្រូវ ហើយប្រសិនបើពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌទម្រង់ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យជាផ្លូវការ ។ ប្រសិនបើពាក្យស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវធ្វើការបដិសេធ ។

**ប្រការ១៤.- ការត្រួតពិនិត្យខ្លឹមសារ**

១. យ៉ាងយូរក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបំពេញតាមលក្ខខណ្ឌតម្រូវ និងការចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ដូចមានចែងក្នុងកថាខណ្ឌ (២) មាត្រា ៩ នៃច្បាប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ ។

២. ប្រសិនបើពាក្យស្នើសុំនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការចុះបញ្ជី ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនោះក្នុងបញ្ជី ។

៣. ក្នុងករណីដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញាពិចារណាឃើញថា ពាក្យស្នើសុំណាមួយត្រូវបដិសេធ ឬតម្រូវឱ្យមានការកែសម្រួល នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ឬការកែសម្រួលនោះ ។

៤. អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង អាចឆ្លើយតបដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេលមិនលើសពី ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបាននូវសេចក្តីជូនដំណឹងពីនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។ ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង មិនបានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ (៣) និង (៤) នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការបដិសេធពាក្យស្នើសុំនោះ ដោយធ្វើការជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ។

៥. ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ (៣) ក្នុងរយៈពេលមិនលើសពី ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបាននូវការឆ្លើយតបនោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យពាក្យស្នើសុំឡើងវិញ និងធ្វើសេចក្តីសម្រេចក្នុងរយៈពេលមិនលើសពី ៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបាននូវការឆ្លើយតប ដូចមានចែងក្នុងកថាខណ្ឌ (៤) ។

៦. ក្នុងករណីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ឯកភាពទៅលើទឡ្ហីករណ៍ក្នុងការឆ្លើយតបដូចមានចែងក្នុងកថាខណ្ឌ (៤) នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រក្នុងបញ្ជី ។

៧. ក្នុងករណីនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម មិនឯកភាពទៅនឹងការឆ្លើយតបដូច

មានចែងក្នុងកថាខណ្ឌ (៤) នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវធ្វើការសម្រេចបដិសេធពាក្យស្នើសុំ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះ ។

៨. ក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធ រាល់កម្រៃសេវាដែលបានបង់មកក្រសួងពាណិជ្ជកម្ម មិនអាចដកវិញបានឡើយ ។

៩. អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាង អាចដាក់ពាក្យបណ្តឹងតវ៉ាទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលមិនលើសពី ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបានទទួលដំណឹងពីសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ។

១០. ការត្រួតពិនិត្យខ្លឹមសារ ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ត្រូវមានការបង់កម្រៃសេវា តាមការកំណត់ ។ ក្នុងករណីកម្រៃនៃការត្រួតពិនិត្យខ្លឹមសារមិនត្រូវបានបង់ ពាក្យស្នើសុំត្រូវបានចាត់ទុកថាបានដកវិញ ។

១១. ក្នុងចំណាត់ការពិនិត្យ និងត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រដូចមានចែងក្នុងប្រការ ១៣ និង ១៤ នៃប្រកាសនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចពន្យារពេលនៃនីតិវិធីបានតែក្នុងករណីចាំបាច់ និងមានហេតុផលសមស្របប៉ុណ្ណោះ ។

## ប្រការ១៥.- ការចុះបញ្ជី និងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ

១. ក្រសួងពាណិជ្ជកម្ម ត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ក្នុងព្រឹត្តិបត្រផ្លូវការក្នុងរយៈពេលមិនលើសពី ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ។

២. ក្នុងករណីម៉ាកសម្គាល់ភូមិសាស្ត្រត្រូវបានចុះបញ្ជីដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ ការបោះពុម្ពផ្សាយត្រូវរួមបញ្ចូលទាំងសេចក្តីសង្ខេបនៃសៀវភៅបន្ទុក ។

៣. សៀវភៅបន្ទុក ត្រូវតម្កល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម សម្រាប់ការប្រឹក្សាយោបល់តាមការស្នើសុំពីបុគ្គលពាក់ព័ន្ធណាមួយ ។

## ប្រការ១៦.- ចំណុចសំខាន់ៗ នៃវិញ្ញាបនបត្រម៉ាកសម្គាល់ភូមិសាស្ត្រ

១. យោងតាមមាត្រា១២នៃច្បាប់ នៅពេលធ្វើការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្រនៃម៉ាកសម្គាល់ភូមិសាស្ត្រជូនម្ចាស់សិទ្ធិ ។

២. វិញ្ញាបនបត្រនេះ ត្រូវមានព័ត៌មានដូចខាងក្រោម៖

- កាលបរិច្ឆេទនៃការចុះបញ្ជី
- លេខចុះបញ្ជី
- សេចក្តីយោងជាមួយនឹងបញ្ជីពាក់ព័ន្ធ
- ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រ
- កាលបរិច្ឆេទនៃការដាក់ពាក្យ
- លេខដាក់ពាក្យ
- ប្រភេទផលិតផលដែលត្រូវការពារតាមរយៈម៉ាកសម្គាល់ភូមិសាស្ត្រ
- ឈ្មោះ និងអាសយដ្ឋានអ្នកដាក់ពាក្យស្នើសុំ

- សេចក្តីយោងរបស់មន្ត្រីត្រួតពិនិត្យ
- ភ្នាក់ងារតំណាងក្នុងស្រុកសម្រាប់ទំនាក់ទំនង
- រូបសញ្ញាជាតិ
- ហត្ថលេខា និងត្រារបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ១៧.- ការកែតម្រូវកំហុសត្រា**

យោងតាមមាត្រា ១៣ នៃច្បាប់ និងផ្អែកតាមការស្នើសុំពីម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រ តាមការណែនាំរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬតាមការផ្តួចផ្តើមរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម អាចកែតម្រូវកំហុសណាមួយក្នុងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ។

**ប្រការ១៨.- ឈ្មោះដែលមានសូរសំឡេងដូចគ្នា**

១. ដូចមានចែងក្នុងកថាខណ្ឌ(៤)មាត្រា១១នៃច្បាប់ ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានស្នើសុំចុះបញ្ជីដែលមានសូរសំឡេងដូចគ្នាទាំងស្រុង ឬដោយផ្អែកទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានបញ្ចូលក្នុងបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានបង្កើតឡើងតាមប្រការ១៩ នៃប្រកាសនេះ ឬដូចទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីរួចមិនអាចចុះបញ្ជីបានឡើយ លើកលែងតែមានភាពញែកដាច់គ្រប់គ្រាន់ ក្នុងការអនុវត្តរវាងលក្ខខណ្ឌប្រើប្រាស់ក្នុងតំបន់ និងតាមប្រពៃណី ហើយរូបភាពបង្ហាញនៃឈ្មោះដែលមានសូរសំឡេងដូចបានចុះបញ្ជីបន្ទាប់ និងម៉ាកសម្គាល់ភូមិសាស្ត្រដែលបានបញ្ចូលក្នុងបញ្ជីរួចហើយ ដោយយកចិត្តទុកដាក់លើតម្រូវការ ដើម្បីធានាឲ្យមានប្រព្រឹត្តិកម្មដោយសមធម៌ដល់ផលិតករពាក់ព័ន្ធ ហើយអ្នកប្រើប្រាស់មិនត្រូវបានបំភ័ន្ត ។

២. ម៉ាកសម្គាល់ភូមិសាស្ត្រដែលមានសូរសំឡេងដូចគ្នា ដែលបំភ័ន្តអ្នកប្រើប្រាស់ឲ្យជឿជាក់ថាផលិតផលនោះមានប្រភពមកពីដែនដីផ្សេងទៀត មិនត្រូវអនុញ្ញាតឲ្យចុះបញ្ជីឡើយ ទោះបីឈ្មោះនោះមានពិតប្រាកដក្នុងដែនដី តំបន់ ឬទីកន្លែងប្រភពដើមជាក់ស្តែងនៃផលិតផលនោះមែនក៏ដោយ ។

៣. ក្រសួងពាណិជ្ជកម្មអាចកំណត់លក្ខខណ្ឌបន្ថែមលើម៉ាកសម្គាល់ភូមិសាស្ត្រ ដែលមានសូរសំឡេងដូចគ្នាដើម្បីឲ្យម៉ាកសម្គាល់ភូមិសាស្ត្រទាំងនោះមានភាពញែកដាច់ពីគ្នា ទើបក្រសួងអនុញ្ញាតឲ្យចុះបញ្ជី ។

**ប្រការ១៩.- បញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ**

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវបង្កើតនិងគ្រប់គ្រងដោយឡែកនូវបញ្ជីស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រ និងឯកសារពាក់ព័ន្ធ ។

## ផ្នែកទី៣

## រូបសញ្ញាជាតិ

**ប្រការ២០.- ការបង្កើតរូបសញ្ញាជាតិ**

រូបសញ្ញាជាតិត្រូវបានបង្កើតឡើងនិងគ្រប់គ្រងដោយក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់លើទំនិញសម្គាល់ភូមិសាស្ត្រ និងម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយរាល់ការប្រើប្រាស់ត្រូវមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ។

**ប្រការ២១.- លក្ខខណ្ឌក្នុងការប្រើប្រាស់រូបសញ្ញាជាតិ**

១. ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារនិងរូបសញ្ញាជាតិ ត្រូវអនុញ្ញាតឲ្យប្រើប្រាស់ចំពោះតែផលិតករ និង/ឬប្រតិបត្តិករណាមួយដែលកំពុងផលិត និង/ឬធ្វើទីផ្សារទំនិញសម្គាល់ភូមិសាស្ត្រណាដែលអនុវត្តតាមសៀវភៅបន្ទុកប៉ុណ្ណោះ ។

២. ក្នុងករណីផលិតផលមានប្រភពក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវធ្វើទីផ្សារក្រោមម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ ត្រូវរំលេចឲ្យឃើញរូបសញ្ញាជាតិលើស្លាកសញ្ញាផលិតផលសម្គាល់ភូមិសាស្ត្រ ។ លើសពីនេះម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីចំពោះផលិតផលណាមួយ ត្រូវរំលេចឲ្យឃើញដូចគ្នាក្នុងការដាក់ស្លាកសញ្ញានោះ ។ ការបញ្ជាក់ឃ្លាថា "ម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារ" ឬពាក្យកាត់ "PGI" អាចរំលេចឲ្យឃើញក្នុងការដាក់ស្លាកសញ្ញានោះផងដែរ ។

៣. ក្នុងករណីផលិតផលនោះមានប្រភពមកពីប្រទេសទីបី ដែលបានធ្វើទីផ្សារក្រោមម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីដូចបានបញ្ជាក់ក្នុងកថាខណ្ឌ (២) ឬរំលេចឲ្យឃើញរូបសញ្ញាជាតិដែលភ្ជាប់ជាមួយនឹងផលិតផលសម្គាល់ភូមិសាស្ត្រ ។

៤. អ្នកប្រើប្រាស់រូបសញ្ញាជាតិ ដោយយោងតាមកថាខណ្ឌ(១) ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ជាមុន នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

៥. ដើម្បីទប់ស្កាត់ទំនិញសម្គាល់ភូមិសាស្ត្រក្លែងក្លាយ និងគ្រប់គ្រងការប្រើប្រាស់រូបសញ្ញាជាតិឲ្យបានកាន់តែមានប្រសិទ្ធភាព នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិកំណត់លក្ខខណ្ឌក្នុងការប្រើប្រាស់បន្ថែមតាមការចាំបាច់ ។

**ប្រការ២២.- អ្នកប្រើប្រាស់រូបសញ្ញាជាតិ**

១. បុគ្គលដែលមានសិទ្ធិប្រើប្រាស់រូបសញ្ញាជាតិ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖
- ជាផលិតករ ឬប្រតិបត្តិករ ដែលជាសមាជិក នៃសមាគមសម្គាល់ភូមិសាស្ត្រ
- អនុវត្តទៅតាមសៀវភៅបន្ទុកនៃម៉ាកសម្គាល់ភូមិសាស្ត្រ ។

២. ការអនុញ្ញាតក្នុងការប្រើប្រាស់រូបសញ្ញាជាតិ ត្រូវបង់កម្រៃដូចមានចែងក្នុងប្រកាសរួម រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

៣. អ្នកប្រើប្រាស់មានសិទ្ធិផលិតដោយផ្ទាល់ខ្លួន នូវស្ទីគ័ររូបសញ្ញាជាតិ ស្លាកសញ្ញា ឬសំបកវេចខ្ចប់ទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ២៣.- ការគ្រប់គ្រងរូបសញ្ញាជាតិ**

១. នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងនិងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលដែលបានអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ ។

២. ក្នុងករណីដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មរកឃើញថា បុគ្គលដែលបានអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ មិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងខាងលើ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិតម្រូវឲ្យបុគ្គលនោះចូលខ្លួនមកបំភ្លឺ និងផ្តល់ព័ត៌មាន ឬផ្តល់ឯកសារ ឬវត្ថុតាងចាំបាច់ដទៃទៀត ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន ។

៣. ការអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ នឹងត្រូវដកហូតក្នុងករណី ដូចខាងក្រោម៖

ក. ប្រសិនបើបុគ្គលដែលបានអនុញ្ញាតប្រើប្រាស់រូបសញ្ញាជាតិ ក្នុងលក្ខខណ្ឌដែលមិនមានចែង នៅក្នុងប្រកាសនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិដកហូតការអនុញ្ញាត ហើយបុគ្គលនោះត្រូវបញ្ឈប់ការប្រើប្រាស់រូបសញ្ញាជាតិនោះ ។

ខ. ក្នុងករណីដែលការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ដោយអនុលោមតាមជំពូកទី ៨ នៃច្បាប់ ត្រូវបានធ្វើមោឃភាព ឬលុបចេញពីបញ្ជី ការអនុញ្ញាតក្នុងការប្រើប្រាស់រូបសញ្ញាជាតិ នឹងត្រូវបានចាត់ទុកថា បានធ្វើមោឃភាព ឬលុបចេញពីបញ្ជីផងដែរ ។

៤. នៅពេលដែលសិទ្ធិប្រើប្រាស់រូបសញ្ញាជាតិត្រូវបានធ្វើមោឃភាព ឬលុបចេញ បុគ្គលដែលទទួលបានការអនុញ្ញាតនោះ ត្រូវប្រគល់ឯកសារអនុញ្ញាតមកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មវិញ ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងសេចក្តីសម្រេចនោះ ។

**ប្រការ២៤.- រយៈពេលនៃការអនុញ្ញាត**

ការអនុញ្ញាតឲ្យប្រើប្រាស់រូបសញ្ញាជាតិ នៅតែមានសុពលភាព ដរាបណាបុគ្គលដែលទទួលបានការអនុញ្ញាតនោះ អនុវត្តតាមវិធាននានានៃម៉ាកសម្គាល់ភូមិសាស្ត្រដែលពាក់ព័ន្ធ ។

## ផ្នែកទី ៤
## បណ្តឹងជំទាស់

**ប្រការ២៥.- មូលដ្ឋានសម្រាប់បណ្តឹងជំទាស់**

១. សេចក្តីថ្លែងហេតុនៃបណ្តឹងជំទាស់ ដូចមានចែងក្នុងមាត្រា ១៥ ដល់ ១៧ នៃច្បាប់ ត្រូវទទួលយកបានតែក្នុងករណី ដែលនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ទទួលបានសេចក្តីថ្លែងហេតុនោះក្នុងរយៈពេលដែលកំណត់ដោយច្បាប់ ហើយប្រសិនបើសេចក្តីថ្លែងហេតុនោះបង្ហាញៈ

ក. ការមិនអនុលោមតាមនិយមន័យនៃម៉ាកសម្គាល់ភូមិសាស្ត្រ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់

ខ. ថាម៉ាកសម្គាល់ភូមិសាស្ត្រដែលបានចុះបញ្ជីនោះ មិនអាចចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្របានដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់ និងប្រកាសនេះ ។

២. មូលដ្ឋានសម្រាប់បណ្តឹងជំទាស់ ត្រូវបានវាយតម្លៃដោយអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ និងដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២៦.- នីតិវិធីប្តឹងជំទាស់ និងការប្រឹក្សាយោបល់**

១. ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជីក្នុងព្រឹត្តិបត្រផ្លូវការ រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលមានផលប្រយោជន៍ស្របច្បាប់ អាចដាក់ពាក្យបណ្តឹងជំទាស់នឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២. ពាក្យបណ្តឹងជំទាស់ ត្រូវភ្ជាប់មកជាមួយសេចក្តីប្រកាសថា ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនោះ ដែលស្ថិតក្រោមមូលដ្ឋាននៃបណ្តឹងជំទាស់ដូចមានចែងក្នុងច្បាប់ និងប្រកាសនេះ ។ ពាក្យបណ្តឹងជំទាស់ដែលមិនមានភ្ជាប់មកជាមួយសេចក្តីប្រកាសនោះ ត្រូវចាត់ទុកជាមោឃៈ ។

៣. ប្រសិនបើពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ហើយបន្ទាប់មកបន្តដាក់សេចក្តីថ្លែងហេតុនៃបណ្តឹងជំទាស់ ក្នុងរយៈពេលកំណត់ខាងលើនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវពិនិត្យភាពដែលអាចទទួលយកបាននៃសេចក្តីថ្លែងហេតុនោះ ។

៤. ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានសេចក្តីថ្លែងហេតុ និងបណ្តឹងជំទាស់ពីដើមបណ្តឹង នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវអញ្ជើញគូភាគីវិវាទដើម្បីចូលរួមប្រឹក្សាយោបល់ក្នុងអំឡុងពេលសមស្រប ដែលមិនត្រូវលើសពី៩០(កៅសិប)ថ្ងៃឡើយ ។

៥. ភាគីទាំងពីរត្រូវចាប់ផ្តើមប្រឹក្សាយោបល់គ្នាដោយគ្មានការពន្យារពេល ហើយត្រូវផ្តល់ឲ្យគ្នាទៅវិញទៅមកនូវព័ត៌មានដែលពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃថា ការចុះបញ្ជីនោះអនុលោម ឬមិនអនុលោមតាមលក្ខខណ្ឌនៃច្បាប់ និងប្រកាសនេះ ។ ប្រសិនបើមាន ឬគ្មានកិច្ចព្រមព្រៀង ព័ត៌មានទាំងនោះត្រូវផ្តល់មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

៦. ក្នុងអំឡុងពេលប្រឹក្សាយោបល់ ប្រសិនបើចាំបាច់ ឬតាមការស្នើសុំពីភាគីណាមួយ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំឲ្យមានសវនាការក្នុងអំឡុងពេលនៃនីតិវិធីប្តឹងជំទាស់ដោយយោងទៅនឹងមាត្រា ១៧ នៃច្បាប់៖

ក. យោងតាមប្រការ ២៦(៤) នៃប្រកាសនេះ សំណើសុំសវនាការត្រូវធ្វើឡើងបន្ទាប់ពីរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការផ្តល់ព័ត៌មានពីការមិនព្រមព្រៀងគ្នា មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។ ក្នុងករណីដែលគ្មានសំណើសុំសវនាការដែលបានធ្វើឡើងក្នុងរយៈពេលខាងលើ និងផ្អែកតាមឆន្ទានុសិទ្ធិដែលកំណត់ដោយច្បាប់ ឬប្រកាស នាយកដ្ឋានកម្មសិទ្ធិបញ្ញាអាចអញ្ជើញភាគីពាក់ព័ន្ធនៃបណ្តឹងជំទាស់មកចូលរួមក្នុងសវនាការ ប្រសិនបើចាំបាច់ ។

ខ. នៅពេលទទួលបានសំណើសុំធ្វើសវនាការ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទនៃការធ្វើសវនាការ ជាមុនយ៉ាងហោចណាស់ ៧(ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ទៅភាគីដែលបានស្នើសុំធ្វើសវនាការ និងភាគីពាក់ព័ន្ធផ្សេងទៀត ។ សវនាការត្រូវធ្វើឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំធ្វើសវនាការ ។

គ. ក្នុងករណីដែលគ្មានសំណើសុំធ្វើសវនាការក្នុងរយៈពេលខាងលើ និងផ្អែកតាមឆន្ទានុសិទ្ធិដែលកំណត់ដោយច្បាប់ ឬប្រកាស នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចធ្វើសេចក្តីសម្រេចរបស់ខ្លួនដោយគ្មានសវនាការឬអញ្ជើញភាគីនៃបណ្តឹងជំទាស់មកធ្វើសវនាការប្រសិនបើចាំបាច់ ។

ឃ. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួនក្នុងអំឡុងពេល ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេច ។

៧. ក្នុងអំឡុងពេល ៩០(កៅសិប)ថ្ងៃ តាមការស្នើសុំពីអ្នកដាក់ពាក្យស្នើសុំ ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួន នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចពន្យារកាលបរិច្ឆេទផុតកំណត់សម្រាប់ការប្រឹក្សាយោបល់ដោយមិនឲ្យលើសពី ៩០(កៅសិប)ថ្ងៃ ។

៨. សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងជំទាស់របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៩. ក្នុងករណីដែលគ្មានបណ្ដឹងជំទាស់តាមជំពូកទី ៣ ផ្នែកទី ៣ នៃច្បាប់ ឬមានបណ្ដឹងជំទាស់ ប៉ុន្តែនៅពេលដែលករណីនោះ អាចត្រូវចេញសេចក្ដីសម្រេចស្ថាពរតាមជំពូកទី៤ នៃច្បាប់ ឬសាលក្រមស្ថាពរទាត់ចោលបណ្ដឹងជំទាស់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវតម្កល់ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនោះ ។

## ជំពូកទី ៤
## នីតិវិធីនៃបណ្ដឹងតវ៉ា

### ប្រការ២៧.- លក្ខខណ្ឌនៃនីតិវិធីបណ្ដឹងតវ៉ា

១. យោងតាមមាត្រា ៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ២១ នៃច្បាប់ បុគ្គលពាក់ព័ន្ធ ឬតំណាងរបស់ខ្លួនអាចដាក់ពាក្យបណ្ដឹងតវ៉ាទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬទៅតុលាការមានសមត្ថកិច្ចប្រឆាំងនឹងសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ។

២. បណ្ដឹងតវ៉ា ដូចមានចែងក្នុងកថាខណ្ឌ(១) ខាងលើ ត្រូវដាក់ជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេលដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ ដោយត្រូវបង់កម្រៃសេវាតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

### ប្រការ២៨.- នីតិវិធីបណ្ដឹងតវ៉ាក្រោមក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ

១. បណ្ដឹងតវ៉ាត្រូវបានលើកទឹកចិត្តឲ្យដាក់ទៅក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ។

២. នៅពេលដែលក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ទទួលបានពាក្យបណ្ដឹងតវ៉ាពីអ្នកដាក់ពាក្យស្នើសុំ ឬពីភាគីពាក់ព័ន្ធណាមួយ ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹងតវ៉ា ត្រូវពិនិត្យភាពដែលអាចទទួលយកបាន ឬមិនបាននៃពាក្យបណ្ដឹងតវ៉ានោះ ។ ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវជូនដំណឹងពីសេចក្ដីសម្រេចរបស់ខ្លួនទៅអ្នកដាក់ពាក្យស្នើសុំ និង/ឬភាគីពាក់ព័ន្ធណាមួយ ។

៣. ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវពិនិត្យខ្លឹមសារនៃបណ្ដឹងតវ៉ាក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹងតវ៉ាជាផ្លូវការ ។ ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវបញ្ជូនសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ពីមូលហេតុរបស់ខ្លួនទៅអ្នកដាក់ពាក្យស្នើសុំ និង/ឬភាគីពាក់ព័ន្ធណាមួយ ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្ដីសម្រេច ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំ និង/ឬភាគីពាក់ព័ន្ធ មិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ អ្នកដាក់ពាក្យស្នើសុំ និង/ឬភាគីពាក់ព័ន្ធនោះ មានសិទ្ធិប្ដឹងទៅតុលាការក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលបានទទួលសេចក្ដីសម្រេចនោះ ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រនឹងចូលជាស្ថាពរ ប្រសិនបើគ្មានបណ្ដឹងតវ៉ាក្នុងអំឡុងពេលនោះ ។

៤. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាទទួលបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រ ឬតុលាការមានសមត្ថកិច្ច ។

## ជំពូកទី ៥
## អានុភាពនៃការចុះបញ្ជី

### ប្រការ២៩.- កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រ

១. ក្នុងករណីដែលម៉ាកសម្គាល់ភូមិសាស្ត្រ មានឈ្មោះផលិតផលជាពាក្យទូទៅ ការប្រើប្រាស់ឈ្មោះទូទៅនោះ មិនត្រូវបានចាត់ទុកថាផ្ទុយនឹងចំណុច (ក) ឬ (ខ) ក្នុងមាត្រា ២៣ នៃច្បាប់ឡើយ ។

២. ពាក្យទូទៅដែលមានក្នុងម៉ាកសម្គាល់ភូមិសាស្ត្រ មិនត្រូវបានការពារឡើយ ។

៣. ម៉ាកសម្គាល់ភូមិសាស្ត្រដែលត្រូវបានការពារ មិនត្រូវក្លាយជាពាក្យទូទៅឡើយ ។

### ប្រការ៣០.- កាលបរិច្ឆេទនៃកិច្ចការពារ

ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជី ។

### ប្រការ៣១.- ពាក្យទូទៅ

ដើម្បីកំណត់ថាពាក្យមួយបានក្លាយទៅជាពាក្យទូទៅ ត្រូវពិចារណាអំពីកត្តាពាក់ព័ន្ធទាំងអស់ ជាពិសេសៈ

១. ស្ថានភាពដែលកើតមានស្រាប់ក្នុងការប្រើប្រាស់

២. ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

### ប្រការ៣២.- កិច្ចការពារដោយអំណាចច្បាប់

អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រសួងពាណិជ្ជកម្ម អាចចាត់វិធានការរដ្ឋបាល ឬតុលាការសមស្រប ដើម្បីទប់ស្កាត់ ឬបញ្ឈប់ការប្រើប្រាស់ដោយខុសច្បាប់ នូវម៉ាកសម្គាល់ភូមិសាស្ត្រដែលបានការពារ ដែលត្រូវផលិត ឬធ្វើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ៣៣.- រយៈពេលអន្តរកាល

ដោយមិនធ្វើឲ្យប៉ះពាល់ដល់ជំពូក ២ នៃច្បាប់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអាចសម្រេចផ្តល់រយៈពេលអន្តរកាលរហូតដល់ ៥(ប្រាំ)ឆ្នាំ ដើម្បីជួយផលិតផលដែលបានកំណត់ឈ្មោះផ្ទុយទៅនឹងមាត្រា ២៣ នៃច្បាប់ បន្តប្រើប្រាស់ឈ្មោះផលិតផលដែលបានធ្វើទីផ្សារ ដោយផ្អែកលើការដាក់លក្ខខណ្ឌជាសេចក្តីថ្លែងដែលអាចគេចផុតពីការប្តឹងជំទាស់ ក្រោមជំពូក ៣ ផ្នែក ៣ នៃច្បាប់ ដោយបង្ហាញថាៈ

១. ការចុះបញ្ជីឈ្មោះនោះ បានធ្វើឲ្យប៉ះពាល់ដល់អត្ថិភាពនៃឈ្មោះ ដែលដូចទាំងស្រុង ឬដោយផ្នែក ឬ

២. ផលិតផលបែបនោះ ត្រូវបានធ្វើទីផ្សារដោយស្របច្បាប់ជាមួយឈ្មោះនោះក្នុងដែនដី ដែលពាក់ព័ន្ធក្នុងរយៈពេលយ៉ាងហោចណាស់ ៥(ប្រាំ)ឆ្នាំ មុនកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជីនោះ ។

## ជំពូក ៦
## ម៉ាកសម្គាល់ភូមិសាស្ត្រ និងការទទួលស្គាល់ ឬការបដិសេធម៉ាក

### ប្រការ៣៤.- ម៉ាកដែលមានកិត្តិសព្ទ ឬល្បី

ឈ្មោះដែលបានស្នើសុំចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រ មិនត្រូវចុះបញ្ជីជូនឡើយ ក្នុងករណីការចុះបញ្ជីឈ្មោះដែលបានស្នើសុំនោះ អាចបំភាន់អ្នកប្រើប្រាស់ចំពោះអត្តសញ្ញាណពិតនៃផលិតផល ដោយសារតែកិត្តិសព្ទ ភាពល្បី និងរយៈពេលនៃការប្រើប្រាស់ម៉ាកនោះ ។

## ជំពូក ៧
## ការត្រួតពិនិត្យអនុលោមភាពតាម
## សៀវភៅបន្ទុកនៃការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ

### ប្រការ៣៥.- អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការត្រួតពិនិត្យម៉ាកសម្គាល់ភូមិសាស្ត្រ

១. អនុលោមតាមមាត្រា ៥ មាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មជាអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរទទួលបន្ទុកត្រួតពិនិត្យជាផ្លូវការ ដើម្បីផ្ទៀងផ្ទាត់ដោយអនុលោមភាពតាមលក្ខខណ្ឌតម្រូវស្របច្បាប់ ដែលទាក់ទងនឹងគម្រោងផែនការម៉ាកសម្គាល់ភូមិសាស្ត្រដូចមានចែងក្នុងប្រកាសនេះ ។

២. អាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងកថាខណ្ឌ (១) ត្រូវផ្តល់កិច្ចធានាឲ្យបានគ្រប់គ្រាន់នូវភាពត្រឹមត្រូវ និងមិនលម្អៀង ហើយត្រូវមានមន្ត្រីជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងធនធានចាំបាច់ដើម្បីអនុវត្តតួនាទីរបស់ខ្លួន ។

### ប្រការ៣៦.- ការត្រួតពិនិត្យលើម៉ាកសម្គាល់ភូមិសាស្ត្រ

ការត្រួតពិនិត្យផ្លូវការ មានដូចខាងក្រោម៖

១. ការផ្ទៀងផ្ទាត់ថា ផលិតផលនោះបានផលិតដោយអនុលោមតាមសៀវភៅបន្ទុក និង

២. ការពិនិត្យតាមដានអំពីការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រ ដែលបានចុះបញ្ជីរួច ដើម្បីពិពណ៌នាផលិតផលដែលបានដាក់លក់លើទីផ្សារ ដោយអនុលោមតាមមាត្រា ២៣ នៃច្បាប់ ។

### ប្រការ៣៧.- ប្រតិភូកម្មឲ្យអង្គភាពត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ច

១. អនុលោមតាមមាត្រា២៦ នៃច្បាប់ អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើប្រតិភូកម្មនូវភារកិច្ចជាក់លាក់ដែលទាក់ទងនឹងការត្រួតពិនិត្យផ្លូវការ នៃគម្រោងផែនការម៉ាកសម្គាល់ភូមិសាស្ត្រទៅឲ្យអង្គភាពត្រួតពិនិត្យមួយ ឬច្រើន ។

២. អង្គភាពចេញវិញ្ញាបនបត្រ ឬអង្គភាពត្រួតពិនិត្យ ជាអាជ្ញាធរសាធារណៈមានសមត្ថកិច្ច ឬអង្គភាពឯកជនដែលទទួលស្គាល់ជាផ្លូវការ ដោយអង្គការស្តង់ដារអន្តរជាតិឬស្ថាប័នណាមួយ ដែលមានប្រព័ន្ធត្រួតពិនិត្យដែលអាចជឿជាក់បាន ។

៣. ការទទួលស្គាល់ដោយយោងទៅនឹងកថាខណ្ឌ (២) នៃប្រការនេះ ត្រូវធ្វើឡើងដោយ៖

ក. អង្គភាពទទួលស្គាល់ថ្នាក់ជាតិ

ខ. អង្គភាពទទួលស្គាល់ក្រៅពីព្រះរាជាណាចក្រកម្ពុជា ដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទទួលស្គាល់ជាពហុភាគី ក្រោមវេទិកាទទួលស្គាល់ជាអន្តរជាតិ ។

### ប្រការ៣៨.- បញ្ជីអង្គភាពចេញវិញ្ញាបនបត្រ និងអង្គភាពត្រួតពិនិត្យ

ក្រសួងពាណិជ្ជកម្ម ត្រូវបង្ហាញឈ្មោះ និងអាសយដ្ឋានអង្គភាពត្រួតពិនិត្យ ឬអង្គភាពចេញវិញ្ញាបនបត្រជា

សាធារណៈដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទាំងនោះតាមកាលកំណត់ ។

**ប្រការ៣៩.- ការទទួលស្គាល់អង្គភាពត្រួតពិនិត្យ ឬចេញវិញ្ញាបនបត្រ**

១. អង្គភាពត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រ ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់ ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ។ អង្គភាពត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រត្រូវស្នើសុំការទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម ដែលត្រូវចេញសេចក្តីសម្រេចក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំ ។

២. អង្គភាពត្រួតពិនិត្យ ឬចេញវិញ្ញាបនបត្រ ត្រូវបានអនុញ្ញាតឲ្យត្រួតពិនិត្យលើផលិតផលសម្គាល់ភូមិសាស្ត្រមួយ ឬច្រើន ។

៣. ការទទួលស្គាល់អង្គភាពត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រ ត្រូវបានផ្តល់ឲ្យក្នុងរយៈពេល ១(មួយ) ឆ្នាំ ។ តាមការស្នើសុំពីអ្នកទទួលផលប្រយោជន៍ ការទទួលស្គាល់នេះអាចបន្តជាថ្មី ដោយអនុវត្តទៅតាមលក្ខខណ្ឌដូចគ្នា ។

**ប្រការ៤០.- ភារកិច្ចរបស់អង្គភាពត្រួតពិនិត្យនិងចេញវិញ្ញាបនបត្រ**

ក្រសួងពាណិជ្ជកម្ម តម្រូវឲ្យអង្គភាពត្រួតពិនិត្យ និងចេញវិញ្ញាបនបត្រដែលបានទទួលស្គាល់បន្តផ្តល់សេវាកម្មតាមសមត្ថកិច្ចរបស់ខ្លួន និងត្រូវផ្តល់ឯកសារ ដើម្បីត្រួតពិនិត្យលើការបំពេញតួនាទី ចំណាត់ការស្របច្បាប់ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យរបស់ខ្លួនជាប្រចាំ យោងតាមមាត្រា ២៦ នៃច្បាប់ ។

## ជំពូក ៨
## ការកែប្រែ មោឃភាព និងការលុបម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី

**ប្រការ៤១.- ការកែប្រែ**

១. ម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រ ឬបុគ្គលពាក់ព័ន្ធ ដែលមានផលប្រយោជន៍ស្របច្បាប់អាចស្នើសុំកែប្រែសៀវភៅបន្ទុកនៃផលិតផលដែលបានចុះបញ្ជី ។ ពាក្យស្នើសុំត្រូវពិពណ៌នា និងផ្តល់មូលហេតុពីការស្នើសុំកែប្រែទាំងនោះ ។

២. ក្នុងករណីដែលការកែប្រែសៀវភៅបន្ទុកមានលក្ខណៈជាសារវន្ត ការស្នើសុំកែប្រែនោះត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងជំពូក ៣ នៃច្បាប់ ។

៣. ប្រសិនបើការស្នើសុំកែប្រែទាំងនោះ មិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការសម្រេចចិត្តចំពោះការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវទទួលស្គាល់ ឬបដិសេធលើការស្នើសុំកែប្រែនោះ ។ ករណីដែលការទទួលស្គាល់លើការកែប្រែនាំដល់ការកែប្រែជាតុនានា ត្រូវយោងដល់នីតិវិធីប្តឹងជំទាស់ជាមុន នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបោះពុម្ពផ្សាយជាតុទាំងនោះក្នុងព្រឹត្តិប័ត្រផ្លូវការ ។ ចំពោះការកែប្រែដែលចាត់ទុកថាមានលក្ខណៈតូចតាច មិនត្រូវ៖

ក. ទាក់ទងនឹងចរិតលក្ខណៈចំបងនៃផលិតផល

ខ. ផ្លាស់ប្តូរចំណងទាក់ទងដូចមានចែងក្នុងចំណុច (៦) នៃសៀវភៅបន្ទុក

គ. មានការផ្លាស់ប្តូរឈ្មោះ ឬផ្នែកណាមួយនៃឈ្មោះផលិតផល

ឃ. ធ្វើឲ្យប៉ះពាល់ដល់តំបន់សម្គាល់ភូមិសាស្ត្រដែលបានកំណត់

ង. ធ្វើឲ្យមានការកើនឡើង នូវការរិតត្បិតដល់ផ្នែកពាណិជ្ជកម្ម លើផលិតផល ឬវត្ថុធាតុដើមនៃផលិតផលនោះ ។

**ប្រការ៤២.- ការលុបម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី**

១. សំណើសុំលុបការចុះបញ្ជីនៃម៉ាកសម្គាល់ភូមិសាស្ត្រ ត្រូវបានលើកទឹកចិត្ត និងត្រូវអនុវត្តទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ ។

២. ក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃសំណើសុំលុប នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវពិនិត្យភាពដែលអាចទទួលយកបាននៃសំណើសុំលុបនោះ ។

៣. នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវអញ្ជើញភាគីដែលបានដាក់សំណើសុំលុប និងម្ចាស់ម៉ាកសម្គាល់ភូមិសាស្ត្រ មកប្រឹក្សាយោបល់ក្នុងរយៈពេលសមស្រប ដោយមិនឲ្យលើសពី ៩០(កៅសិប)ថ្ងៃ ។

៤. ភាគីទាំងពីរ ត្រូវចាប់ផ្តើមប្រឹក្សាយោបល់ដោយឥតពន្យារពេល និងត្រូវផ្តល់ឲ្យគ្នាទៅវិញទៅមកនូវព័ត៌មានពាក់ព័ន្ធ ដើម្បីវាយតម្លៃថាការស្នើសុំលុបការចុះបញ្ជីនោះមានលក្ខណៈស្រប ឬមិនស្រប តាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។ ប្រសិនបើ មិនឈានដល់កិច្ចព្រមព្រៀងរវាងភាគីទាំងពីរព័ត៌មានទាំងនោះត្រូវផ្តល់មកឲ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

៥. ក្នុងអំឡុងពេលប្រឹក្សាយោបល់ ប្រសិនបើចាំបាច់ ឬតាមសំណើសុំពីភាគីណាមួយ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឲ្យមានសវនាការក្នុងអំឡុងពេលនីតិវិធីនៃការលុប ។

ក. សំណើសុំធ្វើសវនាការត្រូវធ្វើឡើងបន្ទាប់ពីរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការផ្តល់ព័ត៌មានពីការ ដែលមិនអាចឈានដល់កិច្ចព្រមព្រៀង មកមន្ត្រីកាន់កាប់បញ្ជី ដោយយោងទៅនឹងកថាខណ្ឌ(៤) ប្រការ៤២ នៃប្រកាសនេះ ។ ក្នុងករណីគ្មានសំណើសុំធ្វើសវនាការក្នុងរយៈពេលខាងលើ និងផ្អែកលើឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជីដែលបានផ្តល់ឲ្យដោយច្បាប់ ឬប្រកាស មន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញភាគីពាក់ព័ន្ធនឹងការស្នើសុំលុបនោះមកធ្វើសវនាការប្រសិនបើចាំបាច់ ។

ខ. នៅពេលដែលទទួលបានសំណើសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទនៃការធ្វើសវនាការជាមុនយ៉ាងហោចណាស់ ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ទៅភាគីដែលបានស្នើសុំធ្វើសវនាការ និងភាគីពាក់ព័ន្ធផ្សេងទៀត ។ ការបើកសវនាការត្រូវរៀបចំឡើងក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់សំណើសុំធ្វើសវនាការ ។

គ. ក្នុងករណីដែលគ្មានសំណើសុំធ្វើសវនាការក្នុងរយៈពេលខាងលើ និងផ្អែកតាមឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជីដែលផ្តល់ឲ្យដោយច្បាប់ ឬប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីអាចធ្វើ សេចក្តីសម្រេចរបស់ខ្លួន ដោយគ្មានធ្វើសវនាការ ឬប្រសិនបើចាំបាច់អាចអញ្ជើញភាគីដែលពាក់ព័ន្ធនឹងការស្នើសុំលុបមកធ្វើសវនាការ ។

ឃ. មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល ១(មួយ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច ។

៦. ក្នុងអំឡុងពេល ៩០(កៅសិប)ថ្ងៃ តាមសំណើពីអ្នកដាក់ពាក្យស្នើសុំ ឬផ្អែកតាមឆន្ទានុសិទ្ធិរបស់

ខ្លួន នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម អាចពន្យារកាលបរិច្ឆេទផុតកំណត់សម្រាប់កិច្ចប្រឹក្សាយោបល់មិនឲ្យលើសពី ៩០(កៅសិប)ថ្ងៃ ។

៧. ត្រូវបោះពុម្ពផ្សាយនូវសេចក្ដីសម្រេចរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលទាក់ទងនឹងការលុបម៉ាកសម្គាល់ភូមិសាស្ត្រចេញពីបញ្ជី ក្នុងព្រឹត្តបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

## ជំពូក ៩
## កម្រៃសេវា

**ប្រការ៤៣.- កម្រៃសេវា**

អ្នកដាក់ពាក្យស្នើសុំការផ្ដល់សេវាពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់កម្រៃសេវា តាមប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

## ជំពូក ១០
## អវសានបញ្ញត្តិ

**ប្រការ៤៤.- ប្រសិទ្ធភាពអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រីប្រចាំការ ប៊ិន ឈិន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៤៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។